សមាគមធានារ៉ាប់រងកម្ពុជា
Insurance Association of Cambodia

# ការធានារ៉ាប់រង÷ ហេតុអ្វីបានជាមានសារៈសំខាន់?

នៅក្នុងប្រទេសអភិវឌ្ឍន៍ទាំងឡាយ ការធានារ៉ាប់រងគឺជាអ្វីមួយដែលគ្រប់ៗគ្នាត្រូវតែមាន និង ជាសំណាញ់សុវត្ថិភាព (Safety Net)។ ការធានារ៉ាប់រងមួយចំនួន ដូចជាការធានារ៉ាបរងយានយន្ត គឺតម្រូវឱ្យមានជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានមនុស្សជាច្រើននៅពុំទាន់មានការយល់ដឹងច្បាស់អំពីសារៈប្រយោជន៍នៃការធានារ៉ាប់រងនៅឡើយ ហើយបានចាត់ទុក ការធានារ៉ាប់រងថា ជាការបង្កើនចំណាយដោយមិនបានគិតថាវាជាការវិនិយោគមួយនោះទេ។ ប្រជាជនយើង ជាច្រើនពុំមានទំនុកចិត្ត និងការជឿជាក់លើការធានារ៉ាប់រង ដោយហេតុផលថា ការធានារ៉ាប់រង គឺជាអ្វីមួយអរូបិយ។ ជាទូទៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រជាជនប្រឈមមុខនឹងហានិភ័យជាច្រើន ដូចជាករណីគ្រោះថ្នាក់ ឬការចំណាយដ៏ច្រើនលើសលប់ពេលចូលមន្ទីរពេទ្យ ដែលប្រការទាំងនេះ នាំឱ្យមានស្ថានភាពធ្លាក់ចុះជាគំហុកនៃសេដ្ឋកិច្ចគ្រួសារ។

ពេលយើងពិនិត្យឱ្យបានស៊ីជម្រៅលើការធានារ៉ាប់រងនោះ យើងនឹងយល់ដឹងច្បាស់ថា វាពិតជាមានសារៈប្រយោជន៍ជាច្រើនដែលយើងមិនបានដឹងពីមុន។ ដំបូង ការធានារ៉ាប់រងធ្វើឱ្យជីវភាពរស់នៅរបស់យើងកាន់តែប្រសើរជាងមុន។ បុគ្គលទាំងឡាយណាដែលពុំមានការធានារ៉ាប់រង ប្រឈមមុខនឹងផលវិបាកជាច្រើនដូចជា***អស្ថិរភាពផ្នែកហិរញ្ញវត្ថុ***។ ឧទាហរណ៍ លោកស្រី រស្មី បានជួបប្រទះនឹងគ្រោះថ្នាក់ពេលគាត់ធ្វើដំណើរមកធ្វើការ កាលពីព្រឹកមិញ ដែលធ្វើឱ្យឡានរបស់គាត់ខូចខាតយ៉ាងធ្ងន់ធ្ងរ។ តើគាត់អាចចំណាយលើការ ជួសជុលដែលអស់ថ្លៃច្រើននេះបានភ្លាមៗទេ? ឧទាហរណ៍មួយទៀត ឧបមាថា ហាងលក់ទំនិញរបស់ សុជាតិ ត្រូវភ្លើងឆេះ តើគាត់អាចមានលុយរាប់ពាន់ដុល្លាភ្លាមៗដើម្បីសាងសង់ហាងឡើងវិញ និងទិញទំនិញដាក់ស្តុកឡើងវិញដែរទេ?

ចម្លើយ គឺយើងដឹងច្បាស់ទាំងអស់គ្នា។ ពួកគេពិតជានឹងត្រូវជួបការលំបាក ហើយត្រូវតស៊ូ ដែលពេលខ្លះមានការខាតបង់ហិរញ្ញវត្ថុយ៉ាងច្រើនលើសលប់។ សម្រាប់បុគ្គលដែលមានការធានារ៉ាប់រង ពួកគេអាចទទួលសំណងនៃការចំណាយនោះមកវិញ។ ស្ថានភាពហិរញ្ញវត្ថុគ្រួសាររបស់ពួកគេ នឹងមិនមានការប៉ះពាល់ ហើយផែនការត្រូវទិញរថយន្តថ្មីនឹងអាចសម្រេចបានតាមការគ្រោងទុក។ ប្រជាជន នៅតែទទួលផលពីការធានារ៉ាប់រងបើទោះបីជាគេមិនបានទាមទារសំណងក៏ដោយ។ ដោយដឹងថាពួកគេមានការការពារដោយការធានារ៉ាប់រងចំពោះហានិភ័យនានា គឺពួកគេមាន **សេចក្តីសុខផ្លូវចិត្ត**។ ចំណុចនេះ មានន័យថា ភាពភ័យខ្លាច និងសេចក្តីតក់ស្លុតត្រូវ

បានកាត់បន្ថយយ៉ាងច្រើន នៅពេលអ្នកត្រូវបានធានារ៉ាប់រងដឹងថា មានការធានារ៉ាប់រងនៅការពារ និងផ្តល់សំណងជូនពួកគេវិញ នៅពេលមានហានិភ័យដែលបានធានាណាមួយកើតឡើង។

ក្រៅពីការធានារ៉ាប់រងទូទៅ នៅមានការធានារ៉ាប់រងអាយុជីវិត ដែលផ្តល់ការការពារ ផ្នែកហិរញ្ញវត្ថុ នៅពេលមានការបាត់បង់ជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង។ ការធានារ៉ាប់រងអាយុជីវិត នឹងផ្តល់សំណងនូវទឹកប្រាក់ដែលបានធានាជូនដល់អ្នកទទួលផល នៅក្នុងស្ថានភាពដែលមាន មរណភាព ឬពិការភាពអចិន្ត្រៃយ៍កើតឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រង។ ការធានារ៉ាប់រងអាយុជីវិត ជួយដល់បុគ្គលម្នាក់ៗដោះស្រាយបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុក្នុងស្ថានភាពដែលព្រឹត្តិការណ៍ដែលមានការធានាបានកើតឡើង ក៏ដូចជាផ្តល់អត្ថប្រយោជន៍នៅថ្ងៃផុតកំណត់បណ្ណសន្យារ៉ាប់រង។ ក្នុងពេល បច្ចុប្បន្ននេះ ការធានារ៉ាប់រងអាយុជីវិតមាននៅព្រះរាជាណាចក្រកម្ពុជា ហើយកំពុងទទួលបាននូវការចាប់អារម្មណ៍ និងការទទួលយកពីសំណាក់ប្រជាពលរដ្ឋយើង ក្នុងការរៀបចំការការពារ និងផែនការផ្នែកហិរញ្ញវត្ថុ។ ផលិតផលសេវាធានារ៉ាប់រងអាយុជីវិត ផ្តល់ទាំងការការពារ និងការសន្សំប្រាក់។

សរុបមក ការធានារ៉ាប់រង (ទាំងការធានារ៉ាប់រងទូទៅ និងការធានារ៉ាប់រងអាយុជីវិត) មានសារៈសំខាន់ណាស់ចំពោះយើងទាំងអស់គ្នា គឺមិនមែនសម្រាប់តែការធានាដែលក្រុមហ៊ុននានាត្រូវទិញនោះទេ។ ពេលពុំមានការធានារ៉ាប់រង បុគ្គលម្នាក់ៗ ក្រុមគ្រួសារនីមួយៗ នឹងពុំមានការការពារ ផ្នែកហិរញ្ញវត្ថុនៅពេលមានបញ្ហាណាមួយកើតឡើង។ ការធានារ៉ាប់រងជីវិត ការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងទ្រព្យសម្បត្តិ និងការធានារ៉ាប់រងផ្សេងៗទៀត សំខាន់ណាស់ចំពោះស្ថិរភាព ផ្នែកហិរញ្ញវត្ថុ សុខមាលភាព និងសេចក្តីសុខផ្លូវចិត្តរបស់មនុស្សយើង។